ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ២៥ ខែកក្កដា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

## **សេចក្តីប្រកាសព័ត៌មាន**
## **ស្តីពី**
## **ការក្លែងបន្លំបង្កើត Account Facebook របស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ ក្រសួង ស្ថាប័ន អង្គភាព អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ក្នុងពេលបច្ចុប្បន្ននេះមានការប្រើប្រាស់នូវ Account Facebook ដែលមានឈ្មោះ "អគ្គនាយកដ្ឋាន ពន្ធដារ (General Department of Taxation)" ដែលបង្ហោះផ្សាយចេញនូវព័ត៌មាន ឯកសារ និងលិខិតផ្សេងៗ ដែលធ្វើឱ្យមានការភ័ន្តច្រឡំថាអគ្គនាយកដ្ឋានពន្ធដារជាអ្នកគ្រប់គ្រង និងផ្សព្វផ្សាយនូវព័ត៌មានទាំងអស់នោះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការបដិសេធទាំងស្រុងថា អគ្គនាយកដ្ឋានពន្ធដារ មិនបានបង្កើត Account Facebook ដែលប្រើប្រាស់ឈ្មោះ អគ្គនាយកដ្ឋាន ពន្ធដារ (General Department of Taxation) ដែលមានអាសយដ្ឋាន https://www.facebook.com/profile.php?id=100008380984211&fref=ts និងរូបភាព ខាងក្រោមនោះទេ។

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់ថា អគ្គនាយកដ្ឋានពន្ធដារមានតែ Facebook Page ដែលមាន ឈ្មោះថា "អគ្គនាយកដ្ឋានពន្ធដារ General Department of Taxation" អាសយដ្ឋាន https://www.facebook.com/cambodiataxation ដោយពុំមានបង្កើតជា Account Facebook នោះទេ ។







**អគ្គនាយកដ្ឋានពន្ធដារ**